# ក្របខណ្ឌមូលបត្របំណុលប្រកបដោយចីរភាព

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ខែធ្នូ ឆ្នាំ២០២៤

## ប្រវត្តិកំណែឯកសារ

| ល.រ | កាលបរិច្ឆេទ | ជំនាន់ | កំណែប្រែ |
|---|---|---|---|
| ១ | ២០ កញ្ញា ២០២៤ | ជំនាន់ទី១ | បង្កើតដំបូង |
| ២ | ៣០ ធ្នូ ២០២៤ | ជំនាន់ទី១ | កំណែប្រែលើកទី១ |

## សង្ខេបលើការកែប្រែ

| កាលបរិច្ឆេទ | មាតិការកែប្រែ | គោលការណ៍ចាស់ | កំណែប្រែថ្មី |
|---|---|---|---|
| ៣០ ធ្នូ ២០២៤ | ចំណុច ២. ការប្រើប្រាស់សាច់ប្រាក់ (Use of Proceeds) | គោលការណ៍មានស្រាប់ | • លុបនូវ (ii). ក្រុមដែលមិនទទួលបានការអប់រំខ្ពស់<br>• កែប្រែនិយមន័យ (iii). គ្រួសារដែលមានចំណូលទាប<br>• កែប្រែនិយមន័យ (iv). សហគ្រាសខ្នាតតូច និងមធ្យម (MSMEs) |
| ៣០ ធ្នូ ២០២៤ | ចំណុច២.១ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន | គោលការណ៍មានស្រាប់ | • កែប្រែលក្ខណៈវិនិច្ឆ័យនៃគម្រោង ឬសកម្មភាពនៃ "ការសន្សំសំចៃថាមពល"<br>• កែប្រែលក្ខណៈវិនិច្ឆ័យនៃគម្រោង ឬសកម្មភាពនៃ "ការដឹកជញ្ជូនដោយគ្មានផ្សែងពុល" |
| ៣០ ធ្នូ ២០២៤ | ចំណុច២.២ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម | គោលការណ៍មានស្រាប់ | • កែប្រែលក្ខណៈវិនិច្ឆ័យផលិតផល នៃ "ការបង្កើតការងារ"<br>• កែប្រែលក្ខណៈវិនិច្ឆ័យផលិតផល និងលក្ខណៈវិនិច្ឆ័យនៃគម្រោង ឬសកម្មភាព នៃ "ការជំរុញសេដ្ឋកិច្ចសង្គម និងការផ្តល់អំណាច"<br>• កែប្រែលក្ខណៈវិនិច្ឆ័យផលិតផល និងលក្ខណៈវិនិច្ឆ័យនៃគម្រោង ឬសកម្មភាព នៃ "ការចូលរួមលើកកម្ពស់ភាពក្រីក្រ" |
| ៣០ ធ្នូ ២០២៤ | ចំណុច ៥.២ របាយការណ៍ផលប៉ះពាល់ (Impact Reporting) ដោយ អិលអូអិលស៊ី | គោលការណ៍មានស្រាប់ | • បន្ថែម "របាយការណ៍ផលប៉ះពាល់ (Impact Reporting) នឹងត្រូវបានត្រួតពិនិត្យដោយក្រុមការងារសវនកម្មផ្ទៃក្នុង ហើយរាយការណ៍ជារៀងរាល់ឆ្នាំរហូតដល់កាលបរិច្ឆេទកំណត់នៃមូលបត្របំណុលប្រកបដោយចីរភាពនេះ។" |
| ៣០ ធ្នូ ២០២៤ | ចំណុច ៥.២.១ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន | គោលការណ៍មានស្រាប់ | • កែប្រែទៅលើ "សូចនាករនៃការអនុវត្តសំខាន់ៗ" |
| ៣០ ធ្នូ ២០២៤ | ចំណុច ៥.២.២ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម | គោលការណ៍មានស្រាប់ | • កែប្រែទៅលើ "សូចនាករនៃការអនុវត្តសំខាន់ៗ" |

## មាតិកា


១. សេចក្តីផ្តើម និងប្រវត្តិស្ថាប័ន ..... ៤

១.១ អំពី អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ..... ៤

១.២ ការចូលរួមចំណែករបស់ អិលអូអិលស៊ី ឆ្ពោះទៅរកការផ្តួចផ្តើមប្រកបដោយចីរភាព ..... ៥

១.៣ ក្របខណ្ឌមូលបត្របំណុលប្រកបដោយចីរភាព ..... ៧

២. ការប្រើប្រាស់សាច់ប្រាក់ (Use of Proceeds) ..... ៨

២.១ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន ..... ៩

២.២ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម ..... ១១

២.៣ ការអនុវត្តដំណើរការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ ..... ១២

២.៣.១ សកម្មភាពដែលត្រូវហាមឃាត់ដោយ អិលអូអិលស៊ី ..... ១២

២.៣.២ ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ..... ១៥

៣. ដំណើរការនៃការវាយតម្លៃ និងការជ្រើសរើសគម្រោង ..... ១៦

៤. ការគ្រប់គ្រងសាច់ប្រាក់ ..... ១៧

៥. របាយការណ៍ ..... ១៧

៥.១ របាយការណ៍បែងចែក (Allocation Reporting) ដោយ អិលអូអិលស៊ី ..... ១៧

៥.២ របាយការណ៍ផលប៉ះពាល់ (Impact Reporting) ដោយ អិលអូអិលស៊ី ..... ១៩

៥.២.១ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន ..... ១៩

៥.២.២ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម ..... ១៩

៦. ការត្រួតពិនិត្យពីភាគីខាងក្រៅ ..... ២០

៦.១ មតិយោបល់ពីភាគីទីពីរ (Second Party Opinion) ..... ២០

៦.២ ការធ្វើសវនកម្មលើរបាយការណ៍ ..... ២០

៦.៣ ការពង្រឹងតម្លាភាព និងការត្រួតពិនិត្យពីភាគីខាងក្រៅបន្ថែម ..... ២០

## ១. សេចក្តីផ្តើម និងប្រវត្តិស្ថាប័ន

### ១.១ អំពី អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ("អិលអូអិលស៊ី") គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជា ដែលមានកិត្តិនាមក្នុងការដោះស្រាយហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្រុមគ្រួសារ សហគ្រិន និងអតិថិជនកម្ពុជា ដែលស្វែងរកឱកាសសេដ្ឋកិច្ចដើម្បីផ្លាស់ប្តូរគុណភាពជីវិតរបស់ពួកគេ។ នៅក្នុងឆ្នាំ១៩៩៤ អិលអូអិលស៊ី ត្រូវបានបង្កើតឡើងជាគម្រោងឥណទាន ដោយអង្គការមិនស្វែងរកប្រាក់ចំណេញ (Catholic Relief Service) ហើយក្រោយមកក៏បានក្លាយទៅជា ធនាគារភូមិ ក្នុងឆ្នាំ២០០២ និងទទួលបានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា នៅក្នុងឆ្នាំ២០០៣។ នៅក្នុងឆ្នាំ២០១៥ ធនាគារភូមិ បានផ្លាស់ប្តូរឈ្មោះមកជា អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ហើយស្របពេលជាមួយគ្នានោះក៏ទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មទទួលប្រាក់បញ្ញើ។ នាពេលបច្ចុប្បន្ននេះ អិលអូអិលស៊ី កំពុងស្ថិតក្រោមការគ្រប់គ្រងដោយក្រុមហ៊ុន LOLC Asia Private Limited និងក្រុមហ៊ុន TPC-ESOP Co, Ltd.។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២៤ អិលអូអិលស៊ី មានទ្រព្យសកម្មសរុបជាង ១,៥៤ពាន់លានដុល្លារអាមេរិក និងបុគ្គលិក ដែលមានបទពិសោធន៍ជាង ៣ពាន់នាក់។ អិលអូអិលស៊ី ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានភាពលេចធ្លោជាងគេមួយនៅក្នុងប្រទេសកម្ពុជាជាមួយទស្សនវិស័យជាស្ថាប័នដែលផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន ដ៏មានទំនុកចិត្តខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា។
បេសកកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ខេមបូឌា) គឺបង្កើតនូវលទ្ធផលវិជ្ជមានយូរអង្វែងដល់សហគមន៍តាមរយៈការផ្តល់នូវ បរិយាបន្នហិរញ្ញវត្ថុ និងការយកចិត្តទុកដាក់ខ្ពស់ចំពោះអតិថិជនប្រកបដោយចីរភាព ព្រមទាំងបង្កើតតម្លៃដល់គ្រប់ភាគីពាក់ព័ន្ធ។

បន្ថែមលើនេះ អិលអូអិលស៊ី បានទទួលវិញ្ញាបនបត្រគោលការណ៍ការពារអតិថិជនពី SMART Campaign តាំងពីឆ្នាំ២០១៥ និងក្នុងខែកុម្ភៈ ឆ្នាំ២០២២ អិលអូអិលស៊ី បានទទួលវិញ្ញាបនបត្រគោលការណ៍ការពារអតិថិជន កម្រិតមាសពីស្ថាប័នវាយតម្លៃអន្តរជាតិ Cerise និង SPTF។ វិញ្ញាបនបត្រកម្រិតមាស គឺជាសមិទ្ធផលកម្រិតខ្ពស់បំផុត និងបង្ហាញថាគ្រឹះស្ថានដែលទទួលបានវិញ្ញាបនបត្រនេះ បំពេញគ្រប់លក្ខខណ្ឌស្តង់ដាកម្រិតខ្ពស់បំផុតនៃការការពារអតិថិជន ស្របតាមស្តង់ដាសាកលនៃការគ្រប់គ្រងសកម្មភាពសង្គម។ អិលអូអិលស៊ី មានបំណងចង់រក្សាបាននូវស្តង់ដាកម្រិតខ្ពស់បំផុត ដែលតម្រូវធ្វើបច្ចុប្បន្នភាពជាទៀងទាត់នៃដំណើរការផ្ទៃក្នុងរបស់ខ្លួន ដើម្បីរួមបញ្ចូលនូវផលិតផលថ្មីៗ (ឧទាហរណ៍៖ ការធានារ៉ាប់រង) និងសម្ភារអប់រំចំណេះដឹងហិរញ្ញវត្ថុ (តាមរយៈការផលិតវីដេអូ និងការផ្សព្វផ្សាយ) និងការផ្តល់វគ្គបណ្តុះបណ្តាល។ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ប្រតិបត្តិការនៅក្នុងវិស័យហិរញ្ញវត្ថុដែលត្រូវបានគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា(NBC)។

ការផ្តល់ជូននូវសមត្ថភាពហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់អតិថិជនក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ បាននាំឱ្យមានការកើនឡើងនូវផលប័ត្រឥណទានសរុបរបស់ខ្លួន។

## ១.២ ការចូលរួមចំណែករបស់ អិលអូអិលស៊ី ឆ្ពោះទៅរកការផ្តួចផ្តើមប្រកបដោយចីរភាព

អិលអូអិលស៊ី ប្តេជ្ញាចិត្តចូលរួមចំណែកឆ្ពោះទៅរកការផ្តួចផ្តើមប្រកបដោយចីរភាព ដោយផ្តោតលើការអនុវត្ត ផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG)។ ដោយទទួលស្គាល់នូវតួនាទីដ៏សំខាន់នៃវិស័យហិរញ្ញវត្ថុក្នុងការ ដោះស្រាយបញ្ហាប្រឈមនៃបរិស្ថាន និងសង្គម អិលអូអិលស៊ី ចូលរួមយ៉ាងសកម្មជាមួយភាគីពាក់ព័ន្ធនៅក្នុង កិច្ចខិតខំប្រឹងប្រែងទាំងនេះ។ នេះរួមបញ្ចូលទាំងអ្នកផ្តល់ប្រាក់កម្ចីដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដែល អិលអូអិលស៊ី ជាអ្នកផ្តល់សេវាហិរញ្ញវត្ថុ និងអតិថិជនដែលចង់បាននូវផលិតផលដែលមិនមានផលប៉ះពាល់ ដល់សង្គម និងបរិស្ថាន។

អិលអូអិលស៊ី បានបង្កើតក្របខណ្ឌមូលបត្របំណុលប្រកបដោយចីរភាពនេះឡើង ដើម្បីចេញនូវមូលបត្រ បំណុលសម្រាប់គាំទ្រដល់បរិស្ថាន សង្គម និងមូលបត្របំណុលប្រកបដោយចីរភាព ដើម្បីប្រើប្រាស់សម្រាប់ការ ផ្តល់ហិរញ្ញប្បទានតាមផ្នែក សម្រាប់គម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគតដែលជួយធ្វើឱ្យ ប្រសើរឡើងក្នុងការទទួលបាននូវថាមពលដែលអាចកកើតឡើងវិញ ក៏ដូចជាការផ្តល់ហិរញ្ញប្បទានដល់សហ គ្រាសធុនតូច និងមធ្យមដែលរួមចំណែកក្នុងគម្រោងជួយលើកកម្ពស់សង្គម។ ក្របខណ្ឌនៃការកំណត់លក្ខណៈ វិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថានចំនួន ៣ និងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើក កម្ពស់សង្គមចំនួន ៥៖

**លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន**

១. ថាមពលកកើតឡើងវិញ

២. ការសន្សំសំចៃថាមពល

៣. ការដឹកជញ្ជូនដោយគ្មានផ្សែងពុល

**លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម**

១. ការបង្កើតការងារ

២. ការជំរុញសេដ្ឋកិចសង្គម និងការផ្តល់អំណាច

៣. ស្ថានភាពលំនៅដ្ឋានកាន់តែប្រសើរ

៤. ការទទួលបានទឹកស្អាត និងអនាម័យ

៥. ការចូលរួមលើកកម្ពស់ភាពក្រីក្រ

ដើម្បីជំរុញដល់ការសម្រេចបាននូវលទ្ធផលតាមគោលបំណងទាំងនេះ អិលអូអិលស៊ី បានដាក់បញ្ចូលការ ពិចារណាផ្នែកបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទៅក្នុងដំណើរការផ្តល់ប្រាក់កម្ចីរបស់ខ្លួន។

ទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងផ្នែកបរិស្ថានរបស់ អិលអូអិលស៊ី បានផ្តួចផ្តើមឱ្យមានប្រព័ន្ធតាមដានមួយ ដើម្បីបង្កើតការវាស់វែងជាមូលដ្ឋានសម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន។ ប្រព័ន្ធនេះត្រួតពិនិត្យពីការប្រើប្រាស់ធនធានផ្ទាល់របស់ អិលអូអិលស៊ី រួមមានការប្រើប្រាស់អគ្គិសនី ការប្រើប្រាស់ទឹក ការប្រើប្រាស់ប្រេងសាំង និងការប្រើប្រាស់ប្រេងម៉ាស៊ូត។

ការចូលរួមលើកកម្ពស់សង្គមរបស់ អិលអូអិលស៊ី បង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការចូលរួមចំណែកសង្គមរួមបញ្ចូលទាំងក្រុមដែលងាយរងគ្រោះ។ មូលដ្ឋានអតិថិជនរបស់ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គមរបស់ អិលអូអិលស៊ី រួមមាន អតិថិជនជាស្ត្រី អតិថិជនរស់នៅជនបទ អតិថិជនដែលពាក់ព័ន្ធនឹងវិស័យកសិកម្មជាដើម។ ជារួម គំនិតផ្តួចផ្តើមរបស់ អិលអូអិលស៊ី បង្ហាញពីការយកចិត្តទុកដាក់របស់ខ្លួនចំពោះការអនុវត្តប្រកបដោយចីរភាព និងតួនាទីយ៉ាងសកម្មរបស់ខ្លួនក្នុងការចូលរួមដោះស្រាយលើបញ្ហាការប្រែប្រួលអាកាសធាតុ។

តាមរយៈផលិតផលជាច្រើនប្រភេទផ្សេងៗគ្នាដែលគាំទ្រលើបរិស្ថាន និងសង្គម អិលអូអិលស៊ី មានបំណងក្នុងការជួយបង្កើននូវផលវិជ្ជមានតាមរយៈផលិតផលហិរញ្ញវត្ថុឯកទេស និងផ្តោតទៅលើការផ្តល់ប្រាក់កម្ចីដូចជាការកែលម្អហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត និងអនាម័យ គាំទ្រគ្រួសារដែលមានប្រាក់ចំណូលទាប សម្របសម្រួលដល់ការកែលម្អលំនៅដ្ឋាន លើកកម្ពស់គំនិតផ្តួចផ្តើមអាជីវកម្មដែលជួយលើកកម្ពស់បរិស្ថាន និងជំរុញភាពជាសហគ្រិន។ ស្របតាមការប្តេជ្ញាចិត្តរបស់ អិលអូអិលស៊ី ផលិតផលខាងក្រោមនេះគឺជាផលិតផលដើម្បីឆ្ពោះទៅរកចីរភាព ទំនួលខុសត្រូវសង្គម និងការផ្តល់សិទ្ធិអំណាចដល់សហគមន៍៖

ក. **ប្រាក់កម្ចីទឹកស្អាត និងអនាម័យ (WIL)** គឺជាផលិតផលពិសេសមួយដែលអាចជួយឱ្យអតិថិជនមានភាពប្រសើរឡើងដោយទទួលបាននូវលក្ខខណ្ឌទឹកស្អាត និងអនាម័យ ក្នុងសហគមន៍របស់ពួកគាត់។ ផលិតផលនេះគាំទ្រនូវគំនិតផ្តួចផ្តើមដូចជា ការសាងសង់ ឬជួសជុលបង្គន់ អណ្តូងទឹក ស្រះទឹក កន្លែងស្តុកទឹក ឬការទិញធុងចម្រោះទឹកស្អាត។ គំនិតផ្តួចផ្តើមនេះគឺស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម។

ខ. អិលអូអិលស៊ី ប្តេជ្ញាចិត្តចូលរួមចំណែកក្នុងការគាំទ្រដល់គ្រួសារដែលមានចំណូលទាប តាមរយៈផលិតផល **ប្រាក់កម្ចីក្រុម (GL)** និងផលិតផល**ប្រាក់កម្ចីឯកត្តជន (IL)** ដោយបានផ្តល់ជាជំនួយហិរញ្ញវត្ថុទៅកាន់អតិថិជនទាំងនោះ។ ការផ្តល់ជូននេះមានគោលបំណងក្នុងការផ្តល់អំណាចដល់គ្រួសារដែលជួបប្រទះការលំបាកដោយអនុញ្ញាតឱ្យពួកគាត់ទទួលបានលទ្ធភាពធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ច និងការរស់នៅប្រកបដោយសុខុមាលភាព។ គំនិតផ្តួចផ្តើមនេះគឺស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម និងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន។

គ. សម្រាប់អតិថិជនដែលចង់ពង្រឹងលើការលើកកម្ពស់នៃគុណភាពជីវិតរបស់ពួកគេតាមរយៈលំនៅដ្ឋាន អិលអូអិលស៊ី នឹងផ្តល់**ប្រាក់កម្ចីកែលម្អគេហដ្ឋាន (HIL)**។ ផលិតផលទាំងនេះអាចឱ្យអតិថិជនជាបុគ្គល

និងគ្រួសារអាចបង្កើតបរិយាកាសនៃការរស់នៅប្រកបដោយសុវត្ថិភាព និងមានផាសុកភាពជាងមុន។ គំនិតផ្ដួចផ្ដើមនេះគឺវាស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម។

ឃ. ការប្ដេជ្ញាចិត្តរបស់ អិលអូអិលស៊ី ឆ្ពោះទៅរកចីរភាព ដោយពង្រីកដល់ការផ្ដល់ប្រាក់កម្ចីដែលជួយលើកកម្ពស់ដល់បរិស្ថាន តាមរយៈការផ្ដល់**ប្រាក់កម្ចីប្រើប្រាស់ផ្ទាល់ខ្លួន (LILAB)** ដែលផ្ដោតលើការគាំទ្រគំនិតផ្ដួចផ្ដើមដែលមិនប៉ះពាល់ដល់បរិស្ថាន។

ង. ស្របតាមបេសកកម្មរបស់ខ្លួនក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងផ្ដល់សិទ្ធិអំណាចដល់សហគ្រិន អិលអូអិលស៊ី បានផ្ដល់ប្រាក់កម្ចីសម្រាប់ការបង្កើតប្រាក់ចំណូល។ ផលប័ត្រឥណទាននេះរួមមាន **ប្រាក់កម្ចីសហគ្រាសធុនតូច និងមធ្យម (SME)** និង**ប្រាក់កម្ចីតាមរដូវកាល (SNL)**។ គំនិតផ្ដួចផ្ដើមនេះគឺវាស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន។

## ១.៣ ក្របខណ្ឌមូលបត្របំណុលប្រកបដោយចីរភាព

អិលអូអិលស៊ី បានបង្កើតក្របខណ្ឌមូលបត្របំណុលប្រកបដោយចីរភាពនេះឡើង ("ក្របខណ្ឌ") ដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រប្រកបដោយចីរភាពដ៏ទូលំទូលាយរបស់ខ្លួនក្នុងគោលបំណងផ្ដោតសំខាន់ទៅលើផលិតផល ឬសម្ភារដែលមានផលវិជ្ជមានដល់បរិស្ថាន និងសង្គម។

ក្របខណ្ឌនេះគឺស្របតាមការណែនាំ ស្ដីពីមូលបត្របំណុលប្រកបដោយចីរភាព (SBG) របស់ ICMA ឆ្នាំ ២០២១ គោលការណ៍មូលបត្របំណុលដែលគាំទ្រដល់បរិស្ថាន (GBP) របស់ ICMA ឆ្នាំ២០២១ និងគោលការណ៍មូលបត្របំណុលដែលគាំទ្រដល់សង្គម (SBP) ឆ្នាំ២០២១ ក៏ដូចជាស្តង់ដាមូលបត្របំណុលអាស៊ានប្រកបដោយចីរភាព (ASUS) ឆ្នាំ២០១៨ ដែលរួមបញ្ចូលគ្នានូវស្តង់ដាមូលបត្របំណុលអាស៊ានដែលគាំទ្រដល់បរិស្ថាន (AGBS) ឆ្នាំ២០១៨ និងស្តង់ដាមូលបត្របំណុលអាស៊ានដែលគាំទ្រដល់សង្គម (AGBS) ឆ្នាំ ២០១៨។

ទាំងនេះគឺជាសំណុំនៃសេចក្ដីណែនាំដោយស្ម័គ្រចិត្តដែលមានគោលបំណងលើកកម្ពស់តម្លាភាព ការបង្ហាញ និងសុចរិតភាពដែលធ្វើឱ្យមានភាពរីកចម្រើននៃទីផ្សារមូលបត្របំណុលដែលគាំទ្រដល់បរិស្ថាន សង្គម និងមូលបត្របំណុលប្រកបដោយចីរភាព។ ក្របខណ្ឌមូលបត្របំណុលប្រកបដោយចីរភាពរបស់ អិលអូអិលស៊ី បម្រើជាក្របខណ្ឌដ៏ទូលំទូលាយដែលអនុញ្ញាតឱ្យស្ថាប័នទទួលបានសិទ្ធិក្នុងការចេញមូលបត្របំណុលប្រកបដោយចីរភាព។

អិលអូអិលស៊ី ធានាឱ្យបាននូវការប្ដេជ្ញាចិត្តរបស់ខ្លួនក្នុងការអនុវត្តតាមសេចក្ដីណែនាំដែលមានចែងក្នុងក្របខណ្ឌនេះសម្រាប់ការចេញមូលបត្របំណុលដែលគាំទ្រដល់បរិស្ថាន សង្គម ឬមូលបត្របំណុលប្រកបដោយចីរភាពដោយរួមបញ្ចូល (១) ការប្រើប្រាស់សាច់ប្រាក់ (២) ការជ្រើសរើស និងការវាយតម្លៃគម្រោង (៣) ការគ្រប់គ្រងសាច់ប្រាក់ និង(៤) របាយការណ៍ដូចដែលមានចែងនៅក្នុងក្របខណ្ឌនេះ។

## ២. ការប្រើប្រាស់សាច់ប្រាក់ ( Use of Proceeds )

សាច់ប្រាក់នៃមូលបត្របំណុលប្រកបដោយចីរភាពនឹងផ្តល់ហិរញ្ញប្បទាន ដល់គម្រោងដែលមានលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និង/ឬសង្គម។ លក្ខណៈវិនិច្ឆ័យនៃគម្រោង និងផលិតផលសម្រាប់ការផ្តល់ហិរញ្ញប្បទានគឺតម្រូវឱ្យបំពេញតាមលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គមរបស់អិលអូអិលស៊ី ហើយត្រូវស្របតាមសេចក្តីណែនាំស្តីពីមូលបត្របំណុលប្រកបដោយចីរភាព (SBG) របស់ ICMA គោលការណ៍មូលបត្របំណុលគាំទ្រដល់បរិស្ថាន (GBP) របស់ ICMA និងគោលការណ៍មូលបត្របំណុលគាំទ្រដល់សង្គម (SBP) ក៏ដូចជាស្តង់ដាមូលបត្របំណុលអាស៊ានប្រកបដោយចីរភាព (ASUS) ផងដែរ ដែលរួមបញ្ចូលគ្នានូវស្តង់ដាមូលបត្របំណុលអាស៊ានដែលគាំទ្រដល់បរិស្ថាន (AGBS) និងស្តង់ដាមូលបត្របំណុលអាស៊ានដែលគាំទ្រដល់សង្គម (ASBS)។

លក្ខណៈវិនិច្ឆ័យនៃគម្រោងដែលជួយលើកកម្ពស់បរិស្ថានគឺតម្រូវឱ្យមានអត្ថប្រយោជន៍ដល់បរិស្ថាន ដូចជាការកាត់បន្ថយកាបូនដែលមានផលប៉ះពាល់ដល់បរិស្ថាន និងភាពងាយរងគ្រោះរបស់សហគមន៍ចំពោះការប្រែប្រួលអាកាសធាតុ។ លក្ខណៈវិនិច្ឆ័យនៃគម្រោងដែលជួយលើកកម្ពស់សង្គមគឺតម្រូវឱ្យមានលទ្ធផលវិជ្ជមានដល់សង្គមតាមរយៈការផ្តល់ប្រាក់កម្ចីសម្រាប់ការបង្កើតការងារ ការពង្រីកអាជីវកម្ម សកម្មភាពកសិកម្ម ទឹកស្អាត ការទទួលបានអនាម័យ និងការកែលម្អគេហដ្ឋាន។ អតិថិជនគោលដៅដែលស្របតាមលក្ខណៈវិនិច្ឆ័យនៃគម្រោងដែលជួយលើកកម្ពស់បរិស្ថាន និងសង្គមរួមមាន៖

(i) បុគ្គល ឬអាជីវកម្ម ដែលប្រើប្រាស់ប្រាក់កម្ចីសម្រាប់គោលបំណងនៃ ថាមពលកកើតឡើងវិញ ប្រសិទ្ធភាពនៃថាមពល (ការសន្សំសំចៃថាមពល) និងយានជំនិះមិនប៉ះពាល់ដល់បរិស្ថាន (Clean transportation) ។

(ii) ក្រុមដែលមិនអាចទទួលបានសេវាហិរញ្ញវត្ថុ ដោយសារកង្វះគុណភាពក្នុងការទទួលបានផលិតផល និងសេវាសំខាន់ៗមានដូចជាស្ត្រី និងអ្នករស់នៅតាមជនបទ។

(iii) គ្រួសារដែលមានចំណូលទាប៖ គ្រួសារដែលមានចំណូលទាប ជាគ្រួសារដែលប្រាក់ចំណូលរបស់ពួកគាត់មានសិទ្ធិទទួលបានប្រាក់កម្ចីដែលមានទំហំរហូតដល់ ៣,០០០ ដុល្លារ។

(iv) សហគ្រាសខ្នាតតូច និងមធ្យម (MSMEs) ដែលប្រតិបត្តិការក្នុងវិស័យផលិតកម្ម ពាណិជ្ជកម្ម សេវាកម្ម និងកសិកម្ម ព្រៃឈើ នេសាទ និងវិស័យផ្សេងៗទៀត។ វាត្រូវបានបែងចែកទៅជាវិស័យនៅក្នុងប្រទេសកម្ពុជា រួមមានកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម និងពាណិជ្ជកម្ម។ សហគ្រាសធុនតូច និងមធ្យមក្នុងវិស័យនីមួយៗត្រូវបានកំណត់ដោយលក្ខណៈវិនិច្ឆ័យចំនួនពីរ៖ ចំនួនបុគ្គលិក និងចំណូលនៃទ្រព្យសកម្មដូចតារាងខាងក្រោម។

| វិស័យ | បរិយាយ | មីក្រូ | ខ្នាតតូច | ធម្យម |
|---|---|---|---|---|
| ផលិតកម្ម | ចំនួនកម្លាំងពលកម្ម FTE | ១ - ២ | ៣ - ៤៩ | ៥០ - ៤៩៩ |
| | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដី) | ក្រោម និង៥០.០០០$ | ៥០.០០០$ - ៥០០.០០០$ | ៥០០.០០០$ - ១.០០០.០០០$ |

| | | | | |
|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ចំនួនកម្លាំងពលកម្ម FTE | ១ - ២ | ៣ - ៤៩ | ៥០ - ១៩៩ |
| | ទ្រព្យសកម្ម | ក្រោម និង៥០.០០០$ | ៥០.០០០$ - ៥០០.០០០$ | ៥០០.០០០$ - ១.០០០.០០០$ |
| ពាណិជ្ជកម្មលក់ដុំ និងលក់រាយ | ចំនួនកម្លាំងពលកម្ម FTE | ១ - ២ | ៣ - ៤៩ | ៥០ - ១៩៩ |
| | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដី និងអគារ) | ក្រោម និង៥០.០០០$ | ៥០.០០០$ - ៥០០.០០០$ | ៥០០.០០០$ - ១.០០០.០០០$ |
| សេវាកម្មផ្សេងៗ | ចំនួនកម្លាំងពលកម្ម FTE | ១ - ៤ | ៥ - ៤៩ | ៥០ - ៩៩ |
| | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដី) | ក្រោម និង៥០.០០០$ | ៥០.០០០$ - ៥០០.០០០$ | ៥០០.០០០$ - ១.០០០.០០០$ |
| សកម្មភាពផ្សេងៗ | ចំនួនកម្លាំងពលកម្ម FTE | ១ - ៩ | ១០ - ៤៩ | ៥០ - ១៩៩ |
| | ទ្រព្យសកម្ម | ក្រោម និង៥០.០០០$ | ៥០.០០០$ - ៥០០.០០០$ | ៥០០.០០០$ - ១.០០០.០០០$ |

FTE = បុគ្គលិកបំពេញការងារពេញម៉ោង MSME = សហគ្រាសខ្នាតតូច សហគ្រាសខ្នាតតូច និងមធ្យម។

អិលអូអិលស៊ី ជ្រើសរើសផលិតផលប្រាក់កម្ចីសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដែលមានទំហំកម្ចីច្រើនជាង ១០.០០០ដុល្លារអាមេរិក ដើម្បីកំណត់អត្តសញ្ញាណសហគ្រាសខ្នាតតូច និងមធ្យម (MSMEs) នោះ។ ដោយសារទិន្នន័យឌីជីថលនៅមានកំណត់ក្នុងប្រព័ន្ធធនាគារស្នូលរបស់ អិលអូអិលស៊ី សហគ្រាសខ្នាតតូច និងមធ្យមនឹងត្រូវបានសន្មត់ថាមានបុគ្គលិកបំពេញការងារពេញម៉ោង (FTE) យ៉ាងតិចពីរនាក់ ដើម្បីធានាបាននូវការប៉ាន់ស្មាន។ គ្រប់គម្រោងបរិស្ថាន និងសង្គមដែលបានកំណត់ក្នុងការឱ្យប្រើប្រាស់ទាំងអស់គួរតែផ្តល់នូវអត្ថប្រយោជន៍ដល់បរិស្ថាន និងសង្គមឱ្យច្បាស់លាស់ ហើយត្រូវបានវាយតម្លៃ និងកំណត់ដោយ អិលអូអិលស៊ី។

## ២.១ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន

លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន គឺសំដៅទៅដល់ការសន្សំសំចៃថាមពលដែលប្រើប្រាស់ចុងក្រោយ ឬថាមពលកកើតឡើងវិញ។ គម្រោងនេះត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យមួយចំនួនដែលកំណត់ក្នុងគម្រោងដើម្បីរួមចំណែកគាំទ្រដល់ការសម្របខ្លួន និងការកាត់បន្ថយហានិភ័យអាកាសធាតុ ឱ្យស្របតាមអាទិភាពនៃអាកាសធាតុរបស់ប្រទេសកម្ពុជា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ លក្ខណៈវិនិច្ឆ័យនេះផងដែរគឺផ្អែកទៅលើការយល់ស្របខាងផ្នែកវិទ្យាសាស្ត្រលើសកម្មភាពណាដែលមានប្រសិទ្ធភាពបំផុតក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុដូចមាននៅក្នុងតារាងខាងក្រោម។ សាច់ប្រាក់ចំណេញសុទ្ធពីមូលបត្របំណុលប្រកបដោយចីរភាពនឹងត្រូវបានបែងចែកទៅឱ្យគម្រោងហិរញ្ញប្បទាន ឬបុនហិរញ្ញប្បទាន និងផលិតផល ឬសម្ភារដែលបានបំពេញតាមលក្ខខណ្ឌនៃលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថានរបស់ អិលអូអិលស៊ី ដូចដែលបានរៀបរាប់ខាងក្រោម៖

| លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន | លក្ខណៈវិនិច្ឆ័យផលិតផល | លក្ខណៈវិនិច្ឆ័យនៃគម្រោង ឬសកម្មភាព |
|---|---|---|
| **ថាមពលកកើតឡើងវិញ** | ស្របតាមលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាននេះ អិលអូអិលស៊ី មានបំណងផ្តល់ហិរញ្ញប្បទានដល់កម្ចីបរិស្ថានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលទាក់ទងនឹងថាមពលកកើតឡើងវិញ (ថាមពលពន្លឺព្រះអាទិត្យ) ដែលមានប្រភពមកពីធនធានធម្មជាតិដែលត្រូវបានបំពេញតាមពេលវេលារបស់មនុស្ស។ | • បច្ចេកវិទ្យា ឬឧបករណ៍នៃការទាញយកថាមពលកកើតឡើងវិញ |
| **ការសន្សំសំចៃថាមពល** | ការផ្តល់ហិរញ្ញប្បទានទៅកាន់កម្ចីដែលមានលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថានគ្រប់គ្រាន់ទាក់ទងនឹងការអភិវឌ្ឍន៍ និងការអនុវត្តផលិតផល ឬបច្ចេកវិទ្យាដែលកាត់បន្ថយការប្រើប្រាស់ថាមពល/ការបំភាយឧស្ម័នកាបូនិក។ | • បច្ចេកវិទ្យាថ្មី ឬឧបករណ៍ដែលជួយកាត់បន្ថយការប្រើប្រាស់ថាមពល/ការសន្សំសំចៃការបំភាយឧស្ម័ន CO2 យ៉ាងហោចណាស់ ២០% រួមបញ្ចូលទាំងប្រភេទយាន្តជំនិះ Hybrid (Hybrid Vehicles)[១] |
| **ការដឹកជញ្ជូនដោយគ្មានផ្សែងពុល** | ការផ្តល់ហិរញ្ញប្បទានទៅកាន់កម្ចីដែលលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថានគ្រប់គ្រាន់ទាក់ទងនឹងយាន្តជំនិះមិនប៉ះពាល់ដល់បរិស្ថាន និងការដឹកជញ្ជូនដោយគ្មានផ្សែងពុលដែលសំដៅលើមធ្យោបាយធ្វើដំណើរដែលបញ្ចេញការបំភាយឧស្ម័នពុលតិចតួច ឬគ្មានការបំពុល និងឧស្ម័នផ្ទះកញ្ចក់។ | • យាន្តជំនិះដែលមិនប៉ះពាល់ដល់បរិស្ថាន និងគម្រោងនៃការដឹកជញ្ជូនដោយគ្មានផ្សែងពុល រួមបញ្ចូលទាំងប្រភេទយាន្តជំនិះអគ្គិសនី (electric vehicles) |

[១]យាន្តជំនិះប្រភេទ Hybrid មួយ ប្រើថាមពលច្រើនជាងមួយដោយរួមបញ្ចូលគ្នានូវការប្រើប្រាស់ម៉ាស៊ីនសាំង ឬម៉ាស៊ូត ដែលមានម៉ូទ័រអេឡិចនិច ហើយប្រព័ន្ធទាំងពីរនេះធ្វើការជាមួយគ្នាដើម្បីរំកិលយានយន្តទៅមុខ។ ដែលនេះគឺអនុញ្ញាតឱ្យយានយន្តដុត ឬប្រើប្រាស់សាំងអស់តិច ទទួលបានប្រសិទ្ធភាពប្រេងឥន្ទនៈកាន់តែប្រសើរជាងការប្រើប្រាស់ម៉ាស៊ីនប្រពៃណី ឬម៉ាស៊ីនធម្មតាដែលប្រើថាមពលប្រេងឥន្ទនៈតែមួយ។

## ២.២ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម

ផលិតផលដែលជួយលើកកម្ពស់សង្គមត្រូវបានកំណត់នៅក្នុងផ្នែកនៃការបង្កើតការងារ ការជំរុញសេដ្ឋកិច្ចសង្គម ការជំរុញសេដ្ឋកិច្ចសង្គម និងការផ្តល់អំណាច ស្ថានភាពលំនៅដ្ឋានកាន់តែប្រសើរ ការទទួលបានទឹកស្អាត និងអនាម័យ ក៏ដូចជាការរួមបញ្ចូលបរិយាបន្នហិរញ្ញវត្ថុ គឺត្រូវបានតម្រឹមជាមួយនឹងការទទួលស្គាល់ដោយគោលការណ៍មូលបត្របំណុលសង្គម (SBP)។ គម្រោងដែលផ្តល់ហិរញ្ញប្បទានក្រោមក្របខណ្ឌនេះនឹងផ្តល់លទ្ធផលវិជ្ជមានដល់សង្គមនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានបង្ហាញជូនដូចក្នុងតារាងខាងក្រោម។ មូលបត្របំណុលនឹងត្រូវបានបែងចែកទៅជាហិរញ្ញប្បទាន ឬបុនហិរញ្ញប្បទានដល់គម្រោង និងផលិតផល ឬសម្ភារដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គមរបស់ អិលអូអិលស៊ី ដូចដែលបានរៀបរាប់ដូចខាងក្រោម ទន្ទឹមនឹងការបំពេញតម្រូវការនៃការបម្រើសេវាកម្មទៅកាន់អតិថិជនគោលដៅរបស់ អិលអូអិលស៊ី ផងដែរ។

| លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម | លក្ខណៈវិនិច្ឆ័យផលិតផល | លក្ខណៈវិនិច្ឆ័យនៃគម្រោង ឬសកម្មភាព |
|---|---|---|
| **ការបង្កើតការងារ** | តាមរយៈលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គមនេះ អិលអូអិលស៊ី មានគោលបំណងផ្តល់ហិរញ្ញប្បទានដល់សហគ្រាសខ្នាតតូច និងមធ្យម (MSMEs) ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលអនុវត្តតាម និងបំពេញតាមនិយមន័យនៃសហគ្រាសខ្នាតតូច និងមធ្យម ដែលមានទំហំកម្ចីច្រើនជាង ១០.០០០ដុល្លារអាមេរិក។ អាជីវកម្មទាំងនោះបានបង្កើតការងារ និង/ឬ អាជីវកម្មដោយខ្លួនឯង (សហគ្រិន)។ | • ប្រាក់កម្ចីសហគ្រាសធុនតូច និងមធ្យម (SME) ដែលគាំទ្រដល់ការបង្កើតការងារនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យម (MSMs)។ |
| **ការជំរុញសេដ្ឋកិច្ចសង្គម និងការផ្តល់អំណាច** | ក្នុងប្រភេទលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គមទាក់ទងនឹង ការជំរុញសេដ្ឋកិច្ចសង្គម និងការផ្តល់អំណាចនេះ (ឱកាសស្មើគ្នា) អិលអូអិលស៊ី នឹងផ្តល់ហិរញ្ញប្បទានជាប្រាក់កម្ចីក្រុម ដល់ក្រុមដែលមិនអាចទទួលបានសេវាហិរញ្ញវត្ថុ (**ស្ត្រីនៅតំបន់ជនបទ**) ក្នុងគោលបំណងដើម្បីពង្រីកសកម្មភាពកសិកម្មខ្នាតតូចរបស់ពួកគាត់ ជាមួយទំហំកម្ចីច្រើនជាង ៣.០០០ដុល្លារអាមេរិក ហើយរហូតដល់ ១០.០០០ដុល្លារអាមេរិក។ | • ប្រាក់កម្ចីឯកត្តជន (IL) ប្រាក់កម្ចីក្រុម (GL) និងប្រាក់កម្ចីតាមរដូវកាល (SNL) ត្រូវបានផ្តល់ដល់អតិថិជនជាស្ត្រី ក្នុងគោលដៅដើម្បីពង្រីកសកម្មភាពកសិកម្មខ្នាតតូចរបស់ពួកគាត់។ |
| **ស្ថានភាពលំនៅដ្ឋានកាន់តែប្រសើរ** | តាមរយៈលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គមនេះ អិលអូអិលស៊ី មានគោលបំណងផ្តល់ហិរញ្ញប្បទានដោយផ្តល់ជូនអតិថិជនប្រាក់កម្ចីទាំងនោះ ដែលត្រូវការជួសជុល ឬក៏ការកែលម្អលំនៅដ្ឋានដែលមាន | • ប្រាក់កម្ចីកែលម្អគេហដ្ឋាន (HIL) អាចធ្វើឱ្យគេហដ្ឋានរបស់អតិថិជនកាន់តែមានផាសុកភាព និង |

| | | |
|---|---|---|
| | ស្រាប់របស់ពួកគាត់ ដើម្បីទទួលបានការរស់នៅកាន់តែប្រសើរឡើង។ | អាចរស់នៅបាន ធ្វើឱ្យគុណភាពជីវិតកាន់តែប្រសើរឡើង។ |
| **ការទទួលបានទឹកស្អាត និងអនាម័យ** | ស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គមទាក់ទងនឹងការទទួលបានទឹកស្អាត និងអនាម័យនេះ អិលអូអិលស៊ី នឹងផ្តល់ហិរញ្ញប្បទានដល់អតិថិជនគោលដៅដើម្បីលើកកម្ពស់សុខភាព សុខុមាលភាព និងគុណភាពជីវិតរបស់ពួកគាត់។ | • ប្រាក់កម្ចីឯកត្តជន (IL) ប្រាក់កម្ចីក្រុម (GL) ប្រាក់កម្ចីសហគ្រាសធុនតូច និងមធ្យម (SME) ប្រាក់កម្ចីទឹកស្អាត និងអនាម័យ (WIL) និងប្រាក់កម្ចីតាមរដូវកាល (SNL) ផ្តល់ឱ្យអតិថិជន ឬប្រជាពលរដ្ឋដើម្បីឱ្យពួកគាត់ទទួលបានការប្រើប្រាស់ទឹកស្អាត មានសុវត្ថិភាព ដែលអាចលើកកម្ពស់សុខភាព សុខុមាលភាព និងគុណភាពជីវិតរបស់ពួកគាត់។ |
| **ការចូលរួមលើកកម្ពស់ភាពក្រីក្រ** | ជាមួយនឹងលក្ខណៈវិនិច្ឆ័យនៃផលិតផលការចូលរួមលើកកម្ពស់ភាពក្រីក្រនេះ អិលអូអិលស៊ី នឹងផ្តល់ហិរញ្ញប្បទានប្រាក់កម្ចីដល់អតិថិជនជាស្ត្រីដែលរស់នៅតំបន់ជនបទដែលខ្វះលទ្ធភាពនៃការទទួលបានប្រភពចំណូល ឬហិរញ្ញវត្ថុ ឬមានប្រាក់ចំណូលស្ថិតក្រោមបន្ទាត់នៃភាពក្រីក្រថ្នាក់ជាតិ ឬប្រាក់ចំណូលក្នុងគ្រួសាររបស់គាត់មានសិទ្ធិទទួលបានប្រាក់កម្ចីដែលមានទំហំរហូតដល់ ៣,០០០ ដុល្លារ។ | • ប្រាក់កម្ចីឯកត្តជន (IL) ប្រាក់កម្ចីក្រុម (GL) និងប្រាក់កម្ចីតាមរដូវកាល (SNL) អាចជួយអតិថិជនជាស្ត្រីដែលរស់នៅតំបន់ជនបទឱ្យចាប់ផ្តើម ឬធ្វើការពង្រីកអាជីវកម្មខ្នាតតូចរបស់ពួកគាគាត់ ដែលអាចនាំឱ្យមានការបង្កើនប្រាក់ចំណូល និងការបង្កើតឱកាសការងារ។ |

*តំបន់ដែលស្ថិតក្រោមការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់ថាជាតំបន់ដែលមានផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់ដែលមានកម្រិតទាបជាងមធ្យមភាគរបស់ប្រទេសកម្ពុជា។*

## ២.៣ ការអនុវត្តដំណើរការផ្តល់ប្រាក់កម្ចីប្រកបដោយទំនួលខុសត្រូវ

### ២.៣.១ សកម្មភាពដែលត្រូវហាមឃាត់ដោយ អិលអូអិលស៊ី

អិលអូអិលស៊ី មិនប្រើប្រាស់សាច់ប្រាក់ដែលបានមកពីផលិតផលប្រាក់កម្ចីលើកកម្ពស់ និងសង្គម ឬផលិតផលប្រាក់កម្ចីប្រកបដោយចីរភាព ដើម្បីផ្តល់ហិរញ្ញប្បទានទៅកាន់គម្រោង ឬសកម្មភាពអាជីវកម្មណាដែលពាក់ព័ន្ធនឹងសកម្មភាពខាងក្រោមដាច់ខាត៖

| លរ | សកម្មភាពដែលត្រូវហាមឃាត់ |
|---|---|
| ១ | ការផលិត ឬការជួញដូរ ដែលផលិតផល ឬសកម្មភាពណាមួយត្រូវចាត់ទុកថាជាសកម្មភាពខុសច្បាប់ចែងដោយច្បាប់ ឬបទប្បញ្ញត្តិរបស់ប្រទេស ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ រួមបញ្ចូលពាក់ព័ន្ធនឹងបរិស្ថាន សុខភាព សុវត្ថិភាព និងវិស័យការងារ។ |
| ២ | ការផលិត ឬការជួញដូរអាវុធ និងគ្រាប់រំសេវ។ |
| ៣ | ការផលិត ឬការជួញដូរភេសជ្ជៈមានជាតិអាល់កុល (មិនរាប់បញ្ចូលស្រាបៀរ និងស្រា)។ |
| ៤ | ការផលិត ឬការជួញដូរថ្នាំជក់។ |
| ៥ | ល្បែងស៊ីសង កាស៊ីណូ និងអាជីវកម្មប្រហាក់ប្រហែល។ |
| ៦ | ការផលិត ការជួញដូរ ការបង្កាត់ពូជ ឬការកាន់កាប់សត្វ រុក្ខជាតិ ឬផលិតផលធម្មជាតិណាមួយ ដែលមានចែងដោយអនុសញ្ញាស្ដីពី ពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វព្រៃ និងរុក្ខជាតិជិតផុតពូជ (CITIES)។ |
| ៧ | ការផលិត ឬការជួញដូរសារធាតុវិទ្យុសកម្ម។ |
| ៨ | ការផលិត ឬការជួញដូរ ឬការប្រើប្រាស់សារធាតុសសៃមិនរលាយ (Unbonded Asbestos Fibers) ហួសកម្រិត។ |
| ៩ | ការធ្វើអាជីវកម្មកាប់ព្រៃឈើលក្ខណៈពាណិជ្ជកម្ម ឬការទិញឧបករណ៍កាប់ឈើសម្រាប់ប្រើប្រាស់នៅក្នុងតំបន់ត្រូពិក។ |
| ១០ | ការផលិត ឬការជួញដូរឱសថ ដែលអន្តរជាតិបញ្ឈប់ ឬហាមឃាត់។ |
| ១១ | ការផលិត ឬការជួញដូរថ្នាំសម្លាប់សត្វល្អិត/ថ្នាំសម្លាប់ស្មៅ ដែលអន្តរជាតិបន្ថយ ឬហាមឃាត់។ |
| ១២ | ការប្រើប្រាស់សំណាញ់នេសាទដែលមានប្រវែងលើសពី ២.៥ គ.ម។ |
| ១៣ | ការផលិត ឬការធ្វើសកម្មភាពដែលប៉ះពាល់ធ្ងន់ធ្ងរ ឬក្នុងទម្រង់កេងប្រវ័ញ្ចលើការងារដោយបង្ខំ ឬប៉ះពាល់ធ្ងន់ធ្ងរលើពលកម្មកុមារ។ |
| ១៤ | ការផលិត ឬការជួញដូរផលិតផលដែលមានសារធាតុគីមី ប៉ូលីក្លូរីនប៊ីហ្វីនីល Polychlorinated Biphenyls (PCBs)។ |
| ១៥ | ការផលិត ឬការជួញដូរអាជីវកម្មណា ដែលបំផ្លាញដល់ស្រទាប់អូហ្សូនត្រូវបានហាមឃាត់ដោយអន្តរជាតិ។ |
| ១៦ | ការផលិត ឬការជួញដូរឈើ ឬផលិតផលបានមកពីព្រៃឈើ។ |
| ១៧ | ការផលិត ការជួញដូរ ការស្តុកទុក ឬការដឹកជញ្ជូនសារធាតុគីមីដែលមានគ្រោះថ្នាក់លើសបរិមាណកំណត់ ឬការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ក្នុងពាណិជ្ជកម្ម។ សារធាតុគីមីដែលមានគ្រោះថ្នាក់រួមមាន៖ ប្រេងសាំង ប្រេងកាត និងផលិតផលប្រេងផ្សេងទៀត។ (មិនរួមបញ្ចូលស្ថានីយប្រេង ឬតូបលក់ប្រេងផ្សេងៗ) |
| ១៨ | ការផលិត ឬការធ្វើសកម្មភាពដែលប៉ះពាល់ដល់ដីកម្មសិទ្ធិ និងទីតាំងដែលមានតម្លៃរបស់សហគមន៍ ឬសហគមន៍ជនជាតិដើមភាគតិច ឬការទាមទារតាមផ្លូវច្បាប់ណាមួយដោយគ្មានឯកសារព្រមព្រៀងពេញលេញពីជនជាតិដើមភាគតិច។ |
| ១៩ | សកម្មភាពអាជីវកម្មដែលបង្កឱ្យមានបញ្ហាជម្លោះដីធ្លី ការបាត់បង់ដីធ្លី ការបាត់បង់សិទ្ធិកាន់កាប់ដីធ្លី ការបាត់បង់ឱកាសក្នុងការទទួលអត្ថប្រយោជន៍ពីការបាត់បង់ដីធ្លី មិនអាចរស់នៅអាស្រ័យផល ឬប្រកបអាជីវកម្មបាន។ និងសកម្មភាពអាជីវកម្មដែលបង្កជម្លៀសពីតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត។ |
| ២០ | សកម្មភាពអាជីវកម្មណាមួយដែលពាក់ព័ន្ធនឹងរូបភាពអាសអាភាស ឬពេស្យាចារ។ |
| ២១ | ជំនួញដែលទាក់ទងនឹងសារធាតុពុលដូចជា ការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) កាបូន (Co2) ការបំពុលទឹក និងការបំពុលដី។ |
| ២២ | គម្រោងដាំដុះនានា ដែលតម្រូវឱ្យមានការកាប់ទន្ទ្រានព្រៃធម្មជាតិ។ |
| ២៣ | ការជួញដូរឆ្លងដែននូវកាកសំណល់ លើកលែងតែការជួញដូរណាដែលអនុញ្ញាតដោយអនុសញ្ញា BALSE និងបទប្បញ្ញត្តិផ្សេងៗដែលបានចែង។ |
| ២៤ | សកម្មភាពអាជីវកម្មក្នុងការផលិត និងបង្កឱ្យមានកាកសំណល់រឹង និងរាវ ដែលមានទំហំធំធេង។ |

| | |
|---|---|
| ២៥ | សកម្មភាពអាជីវកម្មដែលអាចបង្កឱ្យមានការផ្ទុះ ឬបញ្ចេញធូលី ផ្សែង ក្លិនកខ្វក់ និងសំឡេងរំខានខ្លាំង ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព សុវត្ថិភាពការងារ និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅជុំវិញតំបន់ទីតាំងអាជីវកម្ម។ |
| ២៦ | សកម្មភាពអាជីវកម្មដែលមានការប្រើប្រាស់ ទឹក ក្រដាស អគ្គិសនីមានទំហំច្រើនដែលបណ្តាលឱ្យមានការរំខានទៅដល់អ្នកដែលរស់ក្បែរតំបន់ទីតាំងអាជីវកម្ម។ សកម្មភាពប៉ះពាល់ ឬកេងប្រវ័ញ្ចធនធានធម្មជាតិហួសហេតុ។ |
| ២៧ | ការផលិត និងការចែកចាយ ឬការចូលរួមក្នុងសកម្មភាពរើសអើងពូជសាសន៍ ប្រព័ន្ធផ្សព្វផ្សាយលើការប្រឆាំងលទ្ធិប្រជាធិបតេយ្យ ឬប្រព័ន្ធផ្សព្វផ្សាយណាដែលរើសអើងក្រុមណាមួយរបស់ប្រជាជន។ |
| ២៨ | វិស័យដែលជាប់ពាក់ព័ន្ធនឹងផលប៉ះពាល់តិចតួច មានហានិភ័យខ្ពស់ និង/ឬជាកម្មវត្ថុនៃការរំពឹងទុកណាមួយ ឧ. វិស័យអចលនទ្រព្យ។ |
| ២៩ | ការផលិត ឬសេវាកម្មណាមួយដែលត្រូវបានសន្មត់ ឬនាំឱ្យខូចខាតធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ ហើយត្រូវហាមឃាត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ |
| ៣០ | គម្រោងពាក់ព័ន្ធនឹងការសាងសងទំនប់វារីអគ្គិសនីទំហំធំដែលមានផលប៉ះពាល់ខ្លាំង និងមិនអាចកែប្រែត្រឡប់មកសភាពដើមវិញ។ |
| ៣១ | ការធ្វើគម្រោង ឬការធ្វើឱ្យប៉ះពាល់ ឬបាត់បង់សម្បត្តិបេតិកភណ្ឌពិភពលោកបេតិកភណ្ឌវប្បធម៌ ដូចជាទីសក្ការៈបូជា ដីអាស្រ័យផល ភូមិដ្ឋាន ឬសហគមន៍។ |
| ៣២ | ការធ្វើគម្រោង ឬការធ្វើឱ្យប៉ះពាល់ដល់ឧទ្យានជាតិ ឬតំបន់ការពារដែលមានចុះក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ។ |
| ៣៣ | ការទាញយក ឬការសាងសង់គម្រោងរចនាសម្ព័ន្ធ ឬការធ្វើឱ្យប៉ះពាល់ដល់តំបន់ការពារមានកំណត់នៅផ្នែកទី១, ២, ៣ និង ៤ ដោយសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ។ |
| ៣៤ | សកម្មភាពអាជីវកម្មដែលប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរ ដែលបង្កឱ្យមានការបាត់បង់ជីវិត ទីជម្រក និងជំពូកសត្វគ្រប់ប្រភេទ។ សកម្មភាពបង្កឱ្យមានការកើនឡើងនូវប្រភេទសត្វចង្រៃ ការរុករាននូវប្រភេទសត្វចម្លែក ការរីករាលដាលជម្ងឺរាលត្បាត/អាសន្នរោគ។ |
| ៣៥ | មានទីតាំងនៅ ឬនៅជិតទីតាំងដែលងាយរងផលប៉ះពាល់ដល់តំបន់ជាតិ ឬភូមិសាស្ត្រសំខាន់ ដែលអាចបណ្តាលឱ្យមានផលប៉ះពាល់ដល់បរិស្ថាន។ |
| ៣៦ | សូកប៉ាន់ ឬទទួលសំណូក ដែលអាចបកស្រាយបានថាផ្តល់ឥទ្ធិពលដល់ការសម្រេចចិត្តអាជីវកម្ម។ |
| ៣៧ | ចូលរួមវិភាគទានក្នុងនយោបាយ។ ឧទាហរណ៍៖ គណបក្សនយោបាយ ឬបេក្ខជនតំណាងរាស្ត្រ។ |
| ៣៨ | ប្រើប្រាស់ព័ត៌មាន ឬឯកសារសម្ងាត់ ឬព័ត៌មានដែលមិនតម្រូវឱ្យផ្សព្វផ្សាយជាសាធារណៈ។ |
| ៣៩ | បទល្មើសខាងផ្នែកហិរញ្ញវត្ថុ ឬសេដ្ឋកិច្ច រួមបញ្ចូលទាំងបទល្មើសដែលពាក់ព័ន្ធនឹងការសម្អាតប្រាក់។ |
| ៤០ | ការកត់ត្រា ឬរាយការណ៍នូវព័ត៌មានហិរញ្ញវត្ថុ ឬពន្ធខុសច្បាប់ ឬក្លែងបន្លំ។ |
| ៤១ | ប្រតិបត្តិការអាជីវកម្មដែលដាក់តម្លៃទំនិញ ឬសេវាកម្មទាប ឬខ្ពស់ហួសហេតុ។ |
| ៤២ | ឧបករណ៍ ឬវិស័យ ឬសេវាកម្មផ្សេងៗដែលរងទណ្ឌកម្មសេដ្ឋកិច្ចពីអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប ឬប្រទេសបារាំងដោយមិនអាស្រ័យលើទំហំបរិមាណ។ |
| ៤៣ | ការជួញដូរខុសច្បាប់ ឬសកម្មភាពដែលជួយសម្រួលដល់ការចរាចរណ៍ខុសច្បាប់នៃទ្រព្យសម្បត្តិវប្បធម៌។ |
| ៤៤ | សកម្មភាពខុសច្បាប់ដែលពាក់ព័ន្ធនឹងសរីរាង្គ ជាលិកា និងផលិតផលនៃរាងកាយមនុស្ស ឬសកម្មភាពវិស្វកម្មហ្សែនដែលត្រូវបានហាមឃាត់ដោយ ស្តង់ដារជីវវិទ្យាជាតិ នៃប្រទេសបារាំង ឬនៃប្រទេសដែលជាម្ចាស់ផ្ទះ និងតាមស្តង់ដារអឺរ៉ុប ឬអន្តរជាតិដែលអាចអនុវត្តបាន។ |

| | |
|---|---|
| ៤៥ | គម្រោងផ្សេងៗ និងករណីការផ្តល់ហិរញ្ញប្បទានពីវិស័យឯកជន ដែលមានគោលបំណង និង/ឬវិធីសាស្ត្រប្រឆាំងនឹងសិទ្ធិមនុស្ស និងគាំទ្រហេតុផលដែលផ្ទុយយ៉ាងច្បាស់ពីគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីអាជីវកម្ម និងសិទ្ធិមនុស្ស។ |
| ៤៦ | ការចម្រាញ់ប្រេងឆៅ និងការបំប្លែងជាឧស្ម័ន ក៏ដូចជាការបំប្លែងជាសារធាតុរាវ ដោយប្រើធ្យូងថ្ម ៥០០តោន ឬច្រើនជាងនេះក្នុងមួយថ្ងៃ។ |

## ២.៣.២ ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម

ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ត្រូវបានអនុវត្តទៅលើគ្រប់ប្រភេទឥណទានទាំងអស់របស់ អិលអូអិលស៊ី។

- សម្រាប់ឥណទានដែលមានទំហំទាបជាង ៣០.០០០ដុល្លារអាមេរិក ការយល់ដឹងទាក់ទងនឹងបរិស្ថាន និងសង្គមនឹងត្រូវបានលើកយកមកពិភាក្សាជាមួយអតិថិជនដើម្បីឱ្យអតិថិជនទទួលបាននូវការយល់ដឹងពាក់ព័ន្ធនឹងហានិភ័យ និងផ្តល់យោបល់ណែនាំដើម្បីធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើង។
- សម្រាប់ឥណទានសហគ្រាសធុនតូច និងមធ្យម (SME) ដែលមានទំហំចាប់ពី ៣០.០០០ដុល្លារអាមេរិក ការប្រើប្រាស់ឧបករណ៍វិភាគនឹងត្រូវអនុវត្តយ៉ាងពេញលេញនៅក្នុងដំណើរការផ្តល់ឥណទាន។

ការវាយតម្លៃលម្អិតនេះត្រូវបានធ្វើឡើងដើម្បី ពិនិត្យមើលលើផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម ថាតើស្ថិតនៅក្នុងកម្រិតទាប មធ្យម ឬខ្ពស់ជាមួយនឹងការផ្តល់យោបល់ណែនាំដើម្បីកែលម្អ។ ការវាយតម្លៃផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គមត្រូវបានត្រួតពិនិត្យជាប្រចាំដោយក្រុមការងារគ្រប់គ្រងចីរភាព និងក្រុមការងារធានាគុណភាព និងសវនកម្មផ្ទៃក្នុង។ អតិថិជនដែលមានហានិភ័យខ្ពស់ ត្រូវបានជូនដំណឹងទៅកាន់គាត់ទាក់ទងនឹងការចុះទៅត្រួតពិនិត្យក្នុងកំលុងពេលធ្វើសមាជិកភាព ដើម្បីវាយតម្លៃសកម្មភាពរបស់អតិថិជនដែលមានផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន សុខភាព និងសុវត្ថិភាព និងកម្លាំងពលកម្ម ហើយអតិថិជនអាចទទួលបានប្រាក់កម្ចីថ្មីបន្ថែមទៀត ប្រសិនបើសកម្មភាព ឬអាជីវកម្មរបស់គាត់គោរពតាមការការពារហិរញ្ញវត្ថុ និងបរិស្ថាន សុខភាព សុវត្ថិភាព និងកម្លាំងពលកម្ម។ អតិថិជនដែលត្រូវបានគេរកឃើញថាមិនអនុលោមតាមកិច្ចព្រមព្រៀងការពារបរិស្ថាន សុខភាព និងសុវត្ថិភាព និងទិដ្ឋភាពការងារដែលមានចែងក្នុងប្រាក់កម្ចីអាចនឹងប្រមូលប្រាក់កម្ចីត្រលប់មកវិញ ស្របតាមនីតិវិធីរបស់ធនាគារ ហើយប្រហែលជាមិនអាចទទួលបានប្រាក់កម្ចីថ្មីទៀតទេ។ សូមមើលឧបសម្ព័ន្ធទី១៖ ទម្រង់វាយតម្លៃហានិភ័យបរិស្ថាន និងសង្គម។

លើសពីនេះ អិលអូអិលស៊ី នឹងធានាដល់ការការពារអតិថិជន និងការការពារពីការជំពាក់បំណុលហួសកម្រិត តាមរយៈការបង្កើតយន្តការការបង់សងត្រឡប់ប្រាក់កម្ចីរបស់អតិថិជន ការផ្តល់ការអប់រំចំណេះដឹងផ្នែក

ហិរញ្ញវត្ថុសម្រាប់អតិថិជន និងការប្រកាន់ខ្ជាប់នូវស្តង់ដាររបស់ធនាគារជាតិនៃកម្ពុជា និងគោលការណ៍ការពារអតិថិជនរបស់ SMART Campaign។

## ៣. ដំណើរការនៃការវាយតម្លៃ និងការជ្រើសរើសគម្រោង

អិលអូអិលស៊ី នឹងប្រើប្រាស់សាច់ប្រាក់ដែលបានបង្កើតចេញពីមូលបត្របំណុលប្រកបដោយចីរភាពរបស់ខ្លួន ក្នុងការផ្តល់ហិរញ្ញប្បទានទៅដល់គម្រោង ឬផលិតផល ឬសម្ភារថ្មីៗ ដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់។ គោលបំណងគឺដើម្បីបែងចែកជំនួយហិរញ្ញវត្ថុទាំងអស់**ក្នុងរយៈពេលពីរឆ្នាំ**បន្ទាប់ពីការផ្តល់ជូននេះត្រូវបានធ្វើឡើង។ ដំណើរការវាយតម្លៃ និងការជ្រើសរើសគម្រោងរបស់ អិលអូអិលស៊ី ត្រូវបានអនុវត្តតាមរយៈក្រុមការងារមូលបត្របំណុលប្រកបដោយចីរភាពដែលមានសមាសភាពពី តំណាងនៃនាយកដ្ឋានផ្សេងៗ ដែលត្រូវបានសម្របសម្រួលដោយ នាយកដ្ឋានគ្រប់គ្រងចីរភាព (SMD) ហើយមានការត្រួតពិនិត្យពី អនុប្រធាននាយកប្រតិបត្តិ (DCEO)។ នាយិកានាយកដ្ឋានគ្រប់គ្រងចីរភាព (HSMD) មានតួនាទីត្រួតពិនិត្យ និងផ្តល់សេចក្តីណែនាំទៅឱ្យ ប្រធាននាយកប្រតិបត្តិ ដើម្បីអនុម័តទៅលើលក្ខណៈវិនិច្ឆ័យនៃគម្រោងដែលជួយលើកកម្ពស់បរិស្ថាន និងសង្គមបន្ទាប់ពីការជ្រើសរើសដោយនាយកដ្ឋានឥណទានផ្ទាល់។

គម្រោងទាំងអស់ដែលត្រូវបានជ្រើសរើសដោយនាយកដ្ឋានគ្រប់គ្រងចីរភាព (SMD) និងនាយកដ្ឋានឥណទាន ដើម្បីដាក់បញ្ចូលក្នុងផលប័ត្រឥណទាននៃមូលបត្របំណុលប្រកបដោយចីរភាពដែលនឹងត្រូវឆ្លងកាត់ការវាយតម្លៃជាមុន និងឯករាជ្យភាព ដោយផ្អែកលើគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងដើម្បីគ្រប់គ្រងហានិភ័យលើបរិស្ថាន និងសង្គម។ គម្រោងដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ នឹងក្លាយជាផ្នែកមួយនៃផលប័ត្រឥណទាននៃមូលបត្របំណុលប្រកបដោយចីរភាព វានឹងនៅតែមាននៅក្នុងផលប័ត្រឥណទា បើសិនវាមិនត្រូវបានបញ្ចប់ ផុតកាលបរិច្ឆេទកំណត់ ឬលែងបំពេញតាមលក្ខណៈវិនិច្ឆ័យដូចដែលបានរៀបរាប់ខាងលើ។

ការបែងចែកកម្រិតហានិភ័យលើបរិស្ថាន និងសង្គមដោយផ្អែកលើសកម្មភាព និងបញ្ជីចំណាត់ថ្នាក់ហានិភ័យបរិស្ថាន និងសង្គមជាតិ និងអន្តរជាតិ។ គម្រោង ឬសកម្មភាពក្នុងវិស័យនេះត្រូវបានពិនិត្យ ដើម្បីធានាថាបានអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិបរិស្ថាន និងសង្គមជាតិ (ត្រូវការឯកសារពាក់ព័ន្ធ ការអនុញ្ញាត និងអាជ្ញាប័ណ្ណ) ហើយធ្វើការចុះពិនិត្យតាមតំបន់ជាប្រចាំ ដើម្បីពិនិត្យមើលថាអ្នកខ្ចីទាំងអស់ (នីតិករណ៍) បានប្តេជ្ញាដើម្បីគោរព និងអនុវត្តច្បាប់ជាតិនៃបរិស្ថាន សង្គម ការងារ សុខុមាលភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ។

អិលអូអិលស៊ី បានរៀបចំដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមចំពោះផលិតផលកម្ចី និងទំហំកម្ចីទាំងអស់លើការផ្តល់ហិរញ្ញប្បទានដល់គម្រោង មុនពេលដំណើរការជ្រើសរើសគម្រោង ដែលរួមបញ្ចូលនូវឧបករណ៍វាយតម្លៃហានិភ័យ បរិស្ថាន និងសង្គម ដែលមាន ៦សំណួរជុំវិញសសរស្តម្ភចំនួន២នៃកម្រិតហានិភ័យអាជីវកម្មរបស់អ្នកខ្ចី និងគុណភាពនៃការគ្រប់គ្រងហានិភ័យ។

## ៤. ការគ្រប់គ្រងសាច់ប្រាក់

**ការគ្រប់គ្រងប្រាក់មូលនិធិ៖** នាយកដ្ឋានហិរញ្ញវត្ថុនឹងត្រួតពិនិត្យការគ្រប់គ្រងប្រាក់មូលនិធិតាមរយៈវិធីសាស្ត្រ មូលបត្របំណុល-ទៅ-មូលបត្របំណុល (bond-to-bond)។ នាយកដ្ឋានរតនាគារនៃ អិលអូអិលស៊ី នឹងធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់ប្រាក់មូលនិធិពីការផ្តល់ជូននីមួយៗ។ ប្រសិនបើចំណែកនៃសាច់ប្រាក់ពីការចេញមូលបត្របំណុលមិនត្រូវបានប្រើប្រាស់ភ្លាមៗទៅតាមលក្ខណៈវិនិច្ឆ័យនៃផលិតផលនីមួយៗនោះទេ សាច់ប្រាក់ដែលមិនបានប្រើប្រាស់ទាំងនោះនឹងត្រូវបានរក្សាទុកនៅក្នុងប្រភេទ liquid asset រហូតដល់ពេលអាចផ្តល់ឱ្យផលិតផលដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់។ កំលុងពេលនៃការផ្តល់ជូននេះ ប្រសិនបើប្រាក់មូលនិធិដែលបានផ្តល់ហិរញ្ញប្បទានដោយសាច់ប្រាក់បានមកពីមូលបត្របំណុលប្រកបដោយចីរភាព បានឈានដល់កាលបរិច្ឆេទកំណត់ ឬត្រូវបានលក់ចេញ អិលអូអិលស៊ី នឹងបែងចែកចំនួនសាច់ប្រាក់ដែលសមមូលទៅនឹងគម្រោង និងផលិតផលដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់។

**ការចែកចាយប្រាក់មូលនិធិ៖** ការបែងចែកប្រាក់មូលនិធិតាមវិធីសាស្ត្រ មូលបត្របំណុល-ទៅ-មូលបត្របំណុល (bond-to-bond) ត្រូវបានគ្រប់គ្រងយ៉ាងម៉ត់ចត់ដោយនាយកដ្ឋានហិរញ្ញវត្ថុ។ សាច់ប្រាក់ដែលមិនត្រូវបានបែងចែកពីការចេញមូលបត្របំណុលនឹងត្រូវបានរក្សាទុកនៅក្នុងគណនីជា Liquid Asset រហូតដល់ប្រាក់ទាំងនោះអាចបង្វែរទៅជាផលិតផលដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់។ នាយកដ្ឋានរតនាគារនៃ អិលអូអិលស៊ី នឹងធ្វើការត្រួតពិនិត្យដំណើរការនេះ និងធានាថាប្រាក់មូលនិធិត្រូវបានបែងចែកយ៉ាងត្រឹមត្រូវ។

**ការបែងចែកប្រាក់មូលនិធិឡើងវិញ៖** នៅពេលដែលបានផ្តល់ហិរញ្ញប្បទានដោយប្រាក់មូលនិធិដែលបានមកពីមូលបត្របំណុលប្រកបដោយចីរភាពដែលបានឈានដល់កាលបរិច្ឆេទកំណត់ ឬត្រូវបានលក់ អិលអូអិលស៊ី នឹងបែងចែកប្រាក់មូនិធិដែលមានតម្លៃសមមូលទៅនឹងគម្រោង និងផលិតផលដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់។ ដំណើរការនៃការបែងចែកប្រាក់មូលនិធិឡើងវិញនេះធានាបានថា សាច់ប្រាក់ដែលបានពីការចេញមូលបត្របំណុលនេះនឹងបន្តគាំទ្រដល់គំនិតផ្តួចផ្តើមឆ្ពោះទៅកាន់ការអភិវឌ្ឍប្រកបដោយចីរភាព។

## ៥. របាយការណ៍

### ៥.១ របាយការណ៍បែងចែក (Allocation Reporting) ដោយ អិលអូអិលស៊ី

អិលអូអិលស៊ី ខិតខំប្រឹងប្រែងរក្សានូវតម្លាភាព និងគណនេយ្យភាព ក្នុងគោលបំណងបញ្ចេញនូវរបាយការណ៍ស្តីពីការបែងចែកសាច់ប្រាក់ទាក់ទងនឹងការប្រើប្រាស់មូលបត្របំណុលបរិស្ថាន សង្គម និងមូលបត្របំណុលប្រកបដោយចីរភាពរបស់ អិលអូអិលស៊ី ដែលស្ថិតក្រោមក្របខណ្ឌនេះ។ របាយការណ៍នេះនឹងផ្តល់នូវការពិពណ៌នាលម្អិតនៃផលប័ត្រឥណទានដែលមានលក្ខណៈវិនិច្ឆ័យនៃផលិតផលគ្រប់គ្រាន់របស់ អិលអូអិលស៊ី។ អិលអូអិលស៊ី មានការប្តេជ្ញាច្បាស់លាស់ក្នុងការរក្សាបាននូវតម្លាភាព និងគណនេយ្យភាពក្នុងអនុវត្តផ្នែកហិរញ្ញវត្ថុរបស់ខ្លួន ដោយសន្យាថានឹងផ្តល់របាយការណ៍ប្រចាំឆ្នាំរហូតដល់ការបែងចែកសាច់ប្រាក់មានលក្ខណៈពេញ

លេញសម្រាប់ផលិតផលដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ត្រូវបានសម្រេច។ ការប្តេជ្ញានេះធានាឱ្យបានថា បណ្តាភាគីពាក់ព័ន្ធ ត្រូវបានជូនដំណឹងអំពីដំណើរការ និងស្ថានភាពនៃការវិនិយោគ តាមរយៈមូលបត្របំណុលប្រកបដោយចីរភាព។ បន្ថែមពីនេះ អិលអូអិលស៊ី នឹងបន្តធ្វើបច្ចុប្បន្នភាពរបាយការណ៍ទាំងនោះ ប្រសិនបើមានការផ្លាស់ប្តូរសំខាន់ណាមួយក្នុងផលប័ត្រឥណទាននេះ។ ដូច្នេះ អិលអូអិលស៊ី អាចធានាថាព័ត៌មានពាក់ព័ន្ធទាំងអស់នឹងមានការទំនាក់ទំនងរវាងគ្នាប្រកបដោយប្រសិទ្ធភាព រហូតដល់មូលបត្របំណុលប្រកបដោយចីរភាពនេះដល់កាលបរិច្ឆេទកំណត់។ វិធីសាស្ត្រនេះមិនត្រឹមតែបង្ហាញពីការប្តេជ្ញាចំពោះការបែងចែកហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ អិលអូអិល ប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយបង្កើនការទុកចិត្តពីសំណាក់អ្នកវិនិយោគ និងភាគីពាក់ព័ន្ធផ្សេងទៀត ដោយការផ្តល់ព័ត៌មានទាន់ពេលវេលា និងបង្ហាញពីបច្ចុប្បន្នភាពនៃការវិនិយោគរបស់ពួកគេផងដែរ។

របាយការណ៍ប្រចាំឆ្នាំនីមួយៗនឹងត្រូវបានរៀបចំដោយនាយកដ្ឋានគ្រប់គ្រងចីរភាពនឹងរៀបចំជូនគណៈកម្មការចីរភាពដើម្បីពិចារណា និងផ្តល់ជាអនុសាសន៍ទៅកាន់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តក្នុងការធានាឱ្យបានថារបាយការណ៍ទាំងនោះមានភាពត្រឹមត្រូវ និងបំពេញតាមគោលការណ៍។ បន្ទាប់ពីបានការអនុម័ត របាយការណ៍នោះនឹងបង្ហាញជាសាធារណៈនៅលើគេហទំព័រផ្លូវការរបស់ អិលអូអិលស៊ី (https://www.lolc.com.kh/) ។ ការបែងចែករបាយការណ៍របស់ អិលអូអិលស៊ី មានបំណងផ្តល់ជូននូវការបង្ហាញព័ត៌មានដ៏ទូលំទូលាយទាក់ទងនឹងការប្រើប្រាស់សាច់ប្រាក់ពីមូលបត្របំណុលប្រកបដោយចីរភាពរបស់ អិលអូអិលស៊ី។ របាយការណ៍នេះនឹងរួមបញ្ចូលព័ត៌មានដូចខាងក្រោម៖

១. ការពិពណ៌នាដោយសង្ខេបអំពីលក្ខណៈវិនិច្ឆ័យនៃប្រភេទផលិផលដែលសាច់ប្រាក់ត្រូវបានបែងចែក និងចំនួនប្រាក់សរុបដែលបានបែងចែកតាមលក្ខណៈវិនិច្ឆ័យនៃផលិតផលឥណទានគ្រប់គ្រាន់

២. ចំនួនសរុបនៃសាច់ប្រាក់ដែលបានបញ្ចេញហើយមិនទាន់បានបែងចែក (ក្នុងករណីមាន)

៣. សូចនាករនៃបរិមាណគុណភាព និងបរិមាណតួរលេខគិតជាចំនួន (ប្រសិនបើអាចធ្វើបាន) ដែលទាក់ទងនឹងផលប័ត្រឥណទានដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ដូចជា៖

- បរិមាណសរុបនៃមូលបត្របំណុលបរិស្ថាន សង្គម និងមូលបត្របំណុលប្រកបដោយចីរភាពដែលបានបញ្ចេញ
- ចំនួនសរុប និងចំនួនឥណទានដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់
- ការបែងចែកប្រភេទនៃឥណទានដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់
- ការចែកចាយឥណទានដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់តាមភូមិសាស្ត្រ
- សមតុល្យសាច់ប្រាក់ដែលមិនទាន់បានបែងចែក (ក្នុងករណីមាន)
- សមាមាត្រនៃចំនួនសាច់ប្រាក់ដែលប្រើប្រាស់សម្រាប់គោលបំណងហិរញ្ញប្បទាន។

## ៥.២ របាយការណ៍ផលប៉ះពាល់ (Impact Reporting) ដោយ អិលអូអិលស៊ី

របាយការណ៍ផលប៉ះពាល់របស់ អិលអូអិលស៊ី នឹងរួមបញ្ចូលសូចនាករពាក់ព័ន្ធការអនុវត្តសំខាន់ៗ (KPIs) ដែលបង្ហាញជាទម្រង់នៃការកម្រិតប្រភេទមូលបត្របំណុលប្រកបដោយចីរភាពសរុបរបស់ អិលអូអិលស៊ី។

អិលអូអិលស៊ី នឹងផ្តល់នូវសូចនាករដែលមានគុណភាពដូចការរំពឹងទុក និងការសម្រេចបាន ហើយអ្វីដែលអាចធ្វើទៅបាននូវលទ្ធផលចំពោះផលប៉ះពាល់ទៅលើបរិស្ថាន និងសង្គម នៃដែលត្រូវបានបែងចែក។ របាយការណ៍ផលប៉ះពាល់ (Impact Reporting) នឹងត្រូវបានត្រួតពិនិត្យដោយក្រុមការងារសវនកម្មផ្ទៃក្នុង ហើយរាយការណ៍ជារៀងរាល់ឆ្នាំរហូតដល់កាលបរិច្ឆេទកំណត់នៃមូលបត្របំណុលប្រកបដោយចីរភាពនេះ។

នាយកដ្ឋានរតនាគារ នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានឥណទាន និងនាយកដ្ឋានគ្រប់គ្រងចីរភាពរបស់ អិលអូអិលស៊ី ទទួលខុសត្រូវរួមគ្នាក្នុងការរៀបចំរបាយការណ៍គុណភាពលទ្ធផល។ របាយការណ៍នេះមានគោលបំណងលើកកម្ពស់ការប្រៀបធៀប និងតម្លាភាពដោយផ្តល់ព័ត៌មានលម្អិតអំពីសូចនាករលទ្ធផល រួមជាមួយនឹងវិធីសាស្ត្រ និងការសន្មត់ដែលប្រើប្រាស់សម្រាប់ការគណនា។

### ៥.២.១ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់បរិស្ថាន

| លក្ខណៈវិនិច្ឆ័យនៃផលិតផល | សូចនាករនៃការអនុវត្តសំខាន់ៗ |
|---|---|
| ថាមពលកកើតឡើងវិញ | • ការសន្សំសំចៃថាមពលតាមរយៈការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំ (tCO2e)<br>• ចំនួននៃវត្ថុ ឬធាតុដែលបានផ្តល់ហិរញ្ញប្បទាន |
| ការសន្សំសំចៃថាមពល | • ការសន្សំសំចៃថាមពលតាមរយៈការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំ (tCO2e)<br>• ចំនួននៃវត្ថុ ឬធាតុដែលបានផ្តល់ហិរញ្ញប្បទាន |
| យានជំនិះមិនប៉ះពាល់ដល់បរិស្ថាន | • ការសន្សំសំចៃថាមពលតាមរយៈការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រចាំឆ្នាំ ($tCO_2e$)<br>• ចំនួនយានជំនិះអគ្គិសនីដែលបានផ្តល់ហិរញ្ញប្បទាន |

### ៥.២.២ លក្ខណៈវិនិច្ឆ័យនៃផលិតផលដែលជួយលើកកម្ពស់សង្គម

| លក្ខណៈវិនិច្ឆ័យនៃផលិតផល | សូចនាករនៃការអនុវត្តសំខាន់ៗ |
|---|---|
| ការបង្កើតការងារ | • ចំនួនការងារដែលបានបង្កើត ឬជួល<br>• ចំនួនគណនី និងមធ្យមភាគនៃប្រាក់កម្ចីសហគ្រាសខ្នាតតូច និងមធ្យម (MSME) |
| ការជំរុញសេដ្ឋកិច្ចសង្គម និងការផ្តល់អំណាច | • ចំនួនកសិករជាស្ត្រីដែលរស់នៅតាមតំបន់ជនបទដែលទទួលបាន |
| ស្ថានភាពលំនៅដ្ឋានកាន់តែប្រសើរ | • ចំនួននៃគេហដ្ឋានដែលបានជួសជុល ឬកែលម្អផ្ទះ |
| ការទទួលបានទឹកស្អាត និងអនាម័យ | • ចំនួនអតិថិជនដែលទទួលបានការប្រើប្រាស់ផលិតផលទឹកស្អាត និងអនាម័យកាន់តែប្រសើរ (បង្គន់ ធុងចម្រោះទឹក...) និងការតភ្ជាប់ទឹកកាន់តែប្រសើរ (អណ្តូងទឹក ប្រព័ន្ធធារាសាស្ត្រ...) |
| ការចូលរួមលើកកម្ពស់ភាពក្រីក្រ | • ចំនួនប្រាក់កម្ចីដែលបានផ្តល់ទៅកាន់ស្ត្រីដែលមានចំណូលទាប រស់នៅតំបន់ជនបទ |

## ៦. ការត្រួតពិនិត្យពីភាគីខាងក្រៅ

### ៦.១ មតិយោបល់ពីភាគីទីពីរ ( Second Party Opinion )

អិលអូអិលស៊ី ធានាឱ្យបាននូវតម្លាភាព និងភាពរឹងមាំនៃក្របខណ្ឌរបស់ខ្លួន ដោយដាក់ឱ្យមានការផ្ទៀងផ្ទាត់ និងការអនុម័តពីមតិយោបល់របស់ភាគីទីពីរ ដោយការវាយតម្លៃរបស់ Moody's (Moody's Rating)។ ដំណើរការនៃការផ្ទៀងផ្ទាត់នេះគឺបញ្ជាក់ពីការតម្រឹមនៃក្របខណ្ឌជាមួយនឹងស្តង់ដាមូលបត្របំណុលប្រកបដោយចីរភាពរបស់អាស៊ាន និងគោលការណ៍ណែនាំស្តីពីមូលបត្របំណុលប្រកបដោយចីរភាពរបស់ ICMA។ មតិយោបល់ពីភាគីទីពីរ (Second Party Opinion) ដែលទទួលបានពីការវាយតម្លៃរបស់ Moody ត្រូវបានបង្ហាញជាសាធារណៈនៅលើគេហទំព័ររបស់ អិលអូអិលស៊ី ដោយលើកកម្ពស់តម្លាភាព និងគណនេយ្យភាពបន្ថែមទៀតនៅក្នុងការអនុវត្តដំណើរការផ្តល់ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់ អិលអូអិលស៊ី។

### ៦.២ ការធ្វើសវនកម្មលើរបាយការណ៍

អិលអូលអិលស៊ី ធានានូវសុចរិតភាព និងការអនុលោមតាមមូលបត្របំណុលប្រកបដោយចីរភាពរបស់ខ្លួនដែលបានចេញក្រោមក្របខណ្ឌនេះ ដោយមានការចូលរួមពីសវនករខាងក្រៅ ឬអ្នកផ្តល់។ សវនករខាងក្រៅនឹងធ្វើការផ្ទៀងផ្ទាត់ពីភាពពេញលេញទៅនឹងលក្ខណៈវិនិច្ឆ័យនៃផលិតផលដែលបានកំណត់ នៅពេលដែលសាច់ប្រាក់ត្រូវបានបញ្ចេញអស់។ ការផ្ទៀងផ្ទាត់នេះរួមបញ្ចូលទាំងការវាយតម្លៃពីនីតិវិធីអនុម័ត និងការបញ្ជាក់ពីចំនួនទឹកប្រាក់នៃមូលបត្របំណុលប្រកបដោយចីរភាពដែលត្រូវទៅនឹងប្រាក់កម្ចីដែលបានកំណត់ដោយបានបញ្ជាក់នៅក្នុងក្របខណ្ឌនេះ។

### ៦.៣ ការពង្រឹងតម្លាភាព និងការត្រួតពិនិត្យពីភាគីខាងក្រៅបន្ថែម

ការត្រួតពិនិត្យឡើងវិញនៃក្របខណ្ឌនេះនឹងរួមបញ្ចូលនៃការផ្លាស់ប្តូរចំណុចសំខាន់ៗតាមរយៈគោលការណ៍មូលបត្របំណុលប្រកបដោយចីរភាព (SBG) របស់ ICMA គោលការណ៍មូលបត្របំណុលដែលគាំទ្រដល់បរិស្ថាន (GBP) របស់ ICMA និងគោលការណ៍មូលបត្របំណុលដែលគាំទ្រដល់សង្គម (SBP) ឬការអភិវឌ្ឍន៍ដែលទាក់ទងនឹងស្តង់ដាមូលបត្របំណុលអាស៊ានប្រកបដោយចីរភាព (ASUS) ដែលរួមបញ្ចូលគ្នានូវស្តង់ដាមូលបត្របំណុលអាស៊ានដែលគាំទ្រដល់បរិស្ថាន (AGBS) និងស្តង់ដាមូលបត្របំណុលអាស៊ានដែលគាំទ្រដល់សង្គម (ASBS)។ វិសោធនកម្ម ឬការកែប្រែទាំងនេះធ្វើឡើងក្នុងគោលបំណងរក្សា ឬលើកកម្ពស់នៃកម្រិតតម្លាភាព និងរបាយការណ៍ ទន្ទឹមនឹងការណែនាំស្តីពីបទប្បញ្ញត្តិសម្រាប់ការត្រួតពិនិត្យរបស់ភាគីខាងក្រៅដោយអង្គភាព ឬក្រុមហ៊ុនដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ឬមានការទទួលស្គាល់ដោយការប្រកាន់ខ្ជាប់នូវគោលការណ៍ ឬស្តង់ដារដែលមានស្រាប់។

## ទម្រង់វាយតម្លៃហានិភ័យលើបរិស្ថាន និងសង្គម

Effective Date: 01st June 2018

| សំណួរ | ចម្លើយ | | | ពិន្ទុ |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | □. (ពិន្ទុ ១) តិចជាងឬស្មើរ < | □. (ពិន្ទុ ២) ចាប់ពី $200,000 - $300,000; | □. (ពិន្ទុ ៣) ច្រើនជាង $300,000; | |
| ចំនួនអនុម័តកម្ចី | □. (ពិន្ទុ ១) តិចជាងឬស្មើរ ≤ | □. (ពិន្ទុ ២) ចាប់ពី $50,000 - $100,000; | □. (ពិន្ទុ ៣) ច្រើនជាង $100,000; | |
| ប្រភេទហានិភ័យអាជីវកម្ម | (ពិន្ទុ ១): ពាណិជ្ជកម្ម; សេវាកម្មផ្សេងៗ; ផលិតផលផ្សេងៗ; និង កសិកម្ម, រុក្ខាប្រមាញ់ និងនេសាទ ដាំដុះ, បសុសត្វ, ផ្សេងៗ<br>**□ដាំដំណាំ □ចិញ្ចឹមសត្វ □នេសាទ □បើកហាង/លក់រាយ/តូបផ្សារ □ទេសចរណ៍ □ដឹកជញ្ជូន □ជំនួញលក់ដុំ □សំអាងការ □សិប្បកម្ម**<br><br>(ពិន្ទុ ២): សេវាកម្ម (សេវាថែទាំនិងជួសជុលគ្រឿងយន្ត; សេវាកម្មថតនិងផ្តិតរូប); ផលិតកម្ម (ធ្វើឥដ្ឋ, សេរ៉ាមិច / ស្មូនឆ្នាំង / លាបកាចា, ផលិតកញ្ចក់, ដំដែក); ផលិតប្លាស្ទិច (មិនពាក់ព័ន្ធនឹងសារធាតុគីមី), ការផលិតអាហារ, ភេសជ្ជៈ, ផលិតក្រដាស, វាយនភ័ណ្ឌ (កាត់, ដេរ) ជាមួយនឹងការជ្រលក់ពណ៌<br>**□ភោជនីយដ្ឋាន/ហាងតែ □ថែទាំសុខភាព □ផលិតឥដ្ឋ/ /ក្បឿង □ផ្សារដែក/ អេឡិចត្រូនិក □គំនូរ និងបោះពុម្ព □ជួសជុលរថយន្ត/ម៉ូតូ**<br><br>(ពិន្ទុ ៣): សេវាកម្ម (បោកអ៊ុត; គ្រប់គ្រងទឹក និងកាកសំណល់); ផលិតកម្ម (ឧស្សាហកម្មគីមីដែលពាក់ព័ន្ធនឹងការកែច្នៃគីមី; ផលិតផលស្បែក; ការធ្វើធ្យូង, ការទាញយកវត្ថុធាតុដើម); កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រុក្ខាប្រមាញ់ / ផលិតឈើ / បោសសម្អាតព្រៃឈើ)<br>**□កែច្នៃស្បែកសត្វ □កែច្នៃផលិតផលឈើ/ ដែក □ផលិតធ្យូង □អាជីវកម្មដី □រុក្ខាប្រមាញ់ □សំណង់ □ជាងទង** | | | |
| **A: ពិន្ទុមធ្យមនៃកម្រិតហានិភ័យអតិថិជន (ពិន្ទុសរុបចែកនឹង៣)** | | | | |
| កម្រិតយល់ដឹង | □. (ពិន្ទុ ១) មិនមានការយល់ដឹង | □. (ពិន្ទុ ២) យល់ដឹងកម្រិតមូលដ្ឋាន | □. (ពិន្ទុ ៣) យល់ដឹងបានទូលំទូលាយ | |
| ឆន្ទៈនឹងចាត់វិធានការលើផលប៉ះពាល់ | □. (ពិន្ទុ ១) គ្មានឆន្ទៈ | □. (ពិន្ទុ ២) កាត់បន្ថយផលប៉ះពាល់ | □. (ពិន្ទុ ៣) បានបង្ការផលប៉ះពាល់ជាមុន | |
| ការគ្រប់គ្រងបរិស្ថាន និងសង្គម | □. (ពិន្ទុ ១) គ្មានវិធានការ | □. (ពិន្ទុ ២) វិធានការជាមូលដ្ឋាន | □. (ពិន្ទុ ៣) វិធានការជាក់លាក់ | |
| **B: ពិន្ទុមធ្យមនៃគុណភាពក្នុងការគ្រប់គ្រងហានិភ័យអតិថិជន (ពិន្ទុសរុបចែកនឹង៣)** | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| □ ទាប | A = 1&B = 2 | A = 1&B = | A = 1&B = 3 | A = 1&B = 2.67 | A = 1.33&B = 3 | A = 1.33&B = 2.67 | | |
| □ មធ្យម | A = 1&B = 1 | A = 1&B = | A = 1&B = | A = 1.33&B = 1 | A = 1.33&B = 1.33 | A = 1.33&B = 1.67 | A = 1.33&B = 2 | A = 1.33&B = 2.33 |
| | A = 1.67& B = 1 | A = 1.67&B = | A = 1.67&B = | A = 1.67&B = 2 | A = 1.67&B = 2.33 | A = 1.67&B = 3 | A = 1.67&B = 2.67 | A = 2&B = 1.33 |
| | A = 2&B = 1.67 | A = 2&B = 2 | A = 2&B = | A = 2&B = 3 | A = 2&B = 2.67 | A = 2.33&B = 1.67 | A = 2.33&B = 2 | A = 2.33&B = 2.33 |
| | A = 2.33&B = 3 | A = 2.33&B = | A = 3&B = | A = 3&B = 2 | A = 3&B = 2.33 | A = 3&B = 3 | A = 3&B = 2.67 | A = 2.67&B = 1.67 |
| | A = 2.67&B = 2 | A = 2.67&B = | A = 2.67&B = | A = 2.67&B = | | | | |
| □ ខ្ពស់ | A = 2&B = 1 | A = 2.33&B = | A = 2.33&B = | A = 3&B = 1 | A = 3&B = 1.33 | A = 2.67&B = 1 | A = 2.67&B = 1.33 | |

| ការចុះត្រួតពិនិត្យលើកដំបូង | | កាលបរិច្ឆេទ: ......../............../................ | |
|---|---|---|---|
| **បរិស្ថាន [E]** | **បរិស្ថាន សុខភាព និងសុវត្ថិភាព [E] [H&S]** | **សុខភាព និងសុវត្ថិភាព [H&S]** | **ពលកម្ម [L]** |
| ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ ៖ .............. |
| មតិយោបល់កែលម្អ/មតិយោបល់រួម៖........................................................................................................................................ | | | |

| ការចុះត្រួតពិនិត្យតាមដានលើកទី១ សម្រាប់ អតិថិជនមានហានិភ័យមធ្យម ឬខ្ពស់ | | កាលបរិច្ឆេទ: ......../............../................ | |
|---|---|---|---|
| **បរិស្ថាន [E]** | **បរិស្ថាន សុខភាព និងសុវត្ថិភាព [E] [H&S]** | **សុខភាព និងសុវត្ថិភាព [H&S]** | **ពលកម្ម [L]** |
| ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ ៖ .............. |
| មតិយោបល់កែលម្អ/មតិយោបល់រួម៖ ........................................................................................................................................ | | | |
| **ការចុះត្រួតពិនិត្យតាមដានលើកទី២សម្រាប់អតិថិជនមានហានិភ័យមធ្យម ឬខ្ពស់** | | កាលបរិច្ឆេទ: ......../............../................ | |
| **បរិស្ថាន [E]** | **បរិស្ថាន សុខភាព និងសុវត្ថិភាព [E] [H&S]** | **សុខភាព និងសុវត្ថិភាព [H&S]** | **ពលកម្ម [L]** |
| ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ៖ .............. | ចំនួនហានិភ័យ ៖ .............. |
| មតិយោបល់កែលម្អ/មតិយោបល់រួម៖ ........................................................................................................................................ | | | |

| ការត្រួតពិនិត្យលើការវាយតម្លៃលើផលប៉ះពាល់ដល់សង្គម និងបរិស្ថាន | | |
|---|---|---|
| បុគ្គលិកដែលមានឈ្មោះខាងក្រោមបានបញ្ជាក់ថាព័ត៌មានដែលបានប្រមូលគឺពិតប្រាកដត្រឹមត្រូវ និងអនុម័ត ឬបដិសេធពាក្យស្នើសុំកម្ចី ដោយផ្អែកលើគោលនយោបាយការពារបរិស្ថាន និងសង្គម។ | | |
| 1. មន្ត្រីឥណទានបានរៀបចំនិងប្រមូលព័ត៌មានត្រឹមត្រូវ | មតិយោបល់ (ប្រសិនបើមាន): ............................................ | ឈ្មោះ: កាលបរិច្ឆេទ: ....../....../......<br>ហត្ថលេខា: |
| 2. ការបញ្ជាក់របស់ប្រធានមន្ត្រីឥណទាន/នាយកសាខា | មតិយោបល់ (ប្រសិនបើមាន): ............................................ | ឈ្មោះ: កាលបរិច្ឆេទ: ....../....../......<br>ហត្ថលេខា: |
| 3. □ នាយកនាយកដ្ឋានឥណទាន<br>□ នាយក/ នាយិកាសាខា<br>□ អនុម័ត □ មិនអនុម័ត | មតិយោបល់ (ប្រសិនបើមាន): ............................................ | ឈ្មោះ: កាលបរិច្ឆេទ: ....../....../......<br>ហត្ថលេខា: |